# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

~~~~~~~

សាលាដំបូងខេត្តកំពង់ឆ្នាំង

~~~~~

សាលក្រមព្រហ្មទណ្ឌ

-លេខ៦៣(យ)ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩

សំណុំរឿងព្រហ្មទណ្ឌលេខ២៧៦ ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨

សំណុំរឿងស៊ើបសួរលេខ៤០៩ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៨

-សំណុំរឿងជំនុំជម្រះលេខ ១៧០ចុះថ្ងៃទី០៥ខែមិថុនា ឆ្នាំ២០១៩

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពង់ឆ្នាំង

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ វេលាម៉ោង០៨និង៣០នាទីព្រឹក នៅសាលធំ ដោយមានសមាសភាព ដូចខាងក្រោម៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក .. ចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំ ជាប្រធានក្រុមប្រឹក្សា

លោក … ចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំ ជាចៅក្រមប្រឹក្សា

លោក …ចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំ ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក … ជាព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង

### ក្រឡាបញ្ជីសវនាការ

លោក … ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ឆ្នាំ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ២៧៦ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៨ ដែលមាន ជនជាប់ចោទ៖

-ឈ្មោះ **វយស** ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិវៀតណាម សាសនាព្រះពុទ្ធ ទីកន្លែងកំណើតប្រទេសវៀតណាម ទីលំនៅមុនពេលឃុំខ្លួន ភូមិទ្រាត្បូង ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង មុខរបរកម្មករសំណង់ ឪពុកឈ្មោះ ...(រ) ម្តាយឈ្មោះ...(រ) ប្រពន្ធឈ្មោះ ... (រ) មានកូន០៣នាក់ ទោសពីមុនគ្មានជានីតិជន អាចស្តាប់ និងនិយាយភាសាខ្មែរបាន ។

-ដីកាបង្គាប់ឃុំខ្លួនបណ្តោះអាសន្នលេខ១០១១/២០១៨ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៨

-ឈ្មោះ **អបល** ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិម៉ុងបារាំង ឃុំប្អេរ ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ទីលំនៅមុនពេលឃុំខ្លួនភូមិម៉ុងបារាំង សង្កាត់រលាប្អៀរ ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង មុខរបរលក់មីឆា ឪពុកឈ្មោះ ..(រ) ម្តាយឈ្មោះ ... (រ) ប្រពន្ធឈ្មោះ ... (រ) មានកូន០១នាក់ ទោសពីមុនគ្មាន ជានីតិជន ។

-ដីកាបង្គាប់ខ្លួនបណ្តោះអាសន្នលេខ១០១៧/២០១៨ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៨

-ឈ្មោះ **បមរ** អាយុ២៩ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិម៉ុងបារាំង ឃុំប្អេរ ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ទីលំនៅមុនពេលឃុំខ្លួនភូមិម៉ុងបារាំង សង្កាត់រលាប្អៀរ ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង មុខរបរជាងផ្សារដែក ឪពុកឈ្មោះ ...(រ) ម្តាយឈ្មោះ ...(ស) នៅលីវ ទោសពីមុនគ្មាន ជានីតិជន ។

-ដីកាបង្គាប់ខ្លួនបណ្តោះអាសន្នលេខ១០១៣/២០១៨ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៨

-ឈ្មោះ **លសខ** ហៅ ពៅ ភេទស្រី អាយុ២៣ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិក្រុងផ្តិល ឃុំប្រឡាយមាស ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ទីលំនៅមុនពេលឃុំខ្លួន ភូមិទួលក្រឡាញ់ សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង មុខរបរអ្នករត់តុ ឪពុកឈ្មោះ ..(ស) ម្តាយឈ្មោះ ... ម៉ៅ (រ) ប្តីឈ្មោះ **បមរ** (រ) គ្មានកូន ទោសពីមុនគ្មាន ជានីតិជន ។

-ដីកាបង្គាប់ខ្លួនបណ្តោះអាសន្នលេខ១០១៥/២០១៨ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៨

-ឈ្មោះ **យសអ** ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើត ភូមិកណ្តាល ឃុំទី២ ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ទីលំនៅមុនពេលឃុំខ្លួន ភូមិទី០៤ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង មុខរបរមិនពិតប្រាកដ ឪពុកឈ្មោះ...(ស) ម្តាយឈ្មោះ...(រ) ប្រពន្ធឈ្មោះ...(រ) មានកូន០១នាក់ ជានីតិជន។ (គេចខ្លួន)

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ **វយស**, ឈ្មោះ **បមរ** និងឈ្មោះ **លសខ**៖ លោក ឈួន ស៊ីថាន់ ។

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ **អបល**៖ លោក...។

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ **យសអ**៖ លោក...។

ជាប់ចោទពីបទ រក្សាទុក ដឹកជញ្ជូន និងជួញដូរខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចភូមិស្រែតាដៃ ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី០៤-០៥-០៦ ខែធ្នូ ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៨ វេលាម៉ោង១៤និង០០នាទី នៅចំណុចផ្លូវជាតិលេខ៥៣ ស្ថិតក្នុងភូមិស្រែតាដៃលិច ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំ កម្លាំងអធិការនគរបាលស្រុកទឹកផុស សហការជាមួយកម្លាំងជំនាញការិយាល័យប្រឆាំងគ្រឿងញៀន បានចុះបង្ក្រាបបទល្មើសជាក់ស្តែង០១ករណី គឺករណីជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងបន្តចាប់ខ្លួនរហូតដល់ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨ ជាលទ្ធផលឃាត់បានជនជាប់ចោទចំនួន០៥នាក់ គឺឈ្មោះ **បមរ**, ឈ្មោះ **លសខ**, ឈ្មោះ ..., ឈ្មោះ **អបល** និងឈ្មោះ **វយស** និងដកហូតវត្ថុតាងមាន ម្សៅក្រាមពណ៌សថ្លា ជាសារធាតុញៀនមេតំហ្វេតាមីនសរុបចំនួន ៩៦កញ្ចប់ សរុប(ទម្ងន់២៧០,១៦ក្រាម) ថ្នាំញៀនប្រភេទ WY ចំនួន១៨២គ្រាប់ ទម្ងន់(១៩,៦០ក្រាម) ទូរស័ព្ទចំនួន០៤គ្រឿង និងម៉ូតូចំនួន០២គ្រឿង ចំណែកឈ្មោះ **យសអ** បានគេចខ្លួនបាត់ ។

-បានឃើញរបាយការណ៍សំយោគលេខ៣៧៦/២០១៨ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ របស់ការិយាល័យប្រឆាំងគ្រឿងញៀននៃស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ២៤៨៥/១៨ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៨ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង។

-បានឃើញលទ្ធផលកោសល្យវិច័យគ្រឿងញៀនលេខ១៧១៥៧/១៩ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៤ ខែមីនា ឆ្នា២០១៩ របស់មន្ទីពិសោធន៍នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

-បានឃើញលទ្ធផលកោសល្យវិច័យគ្រឿងញៀនលេខ១៧១៥៨/១៩ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៤ ខែមីនា ឆ្នា២០១៩ របស់មន្ទីពិសោធន៍នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

-បានឃើញលទ្ធផលកោសល្យវិច័យគ្រឿងញៀនលេខ១៧១៥៩/១៩ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៤ ខែមីនា ឆ្នា២០១៩ របស់មន្ទីពិសោធន៍នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ៦៣៥អ.យ/២០១៩ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង។

-បានឃើញដីកាដំណោះស្រាយលេខ៣២០/២០១៩ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ឆ្នាំង ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ **លសខ** ហៅ ពៅ បានឆ្លើយថាៈ សមត្ថកិច្ចឃាត់រូបខ្លួនកាលពីថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៨ មូលហេតុព្រោះខ្ញុំជិះម៉ូតូជាមួយឈ្មោះ **បមរ** ដោយឈ្មោះ **បមរ** បបួលខ្លួនទៅលេងរមាស ខ្លួន និងឈ្មោះ **បមរ** ជាសង្សានឹងគ្នា។ ពេលកំពុងជិះម៉ូតូក៏មានសមត្ថកិច្ចឃាត់ពួកខ្លួន ហើយឆែកឃើញគ្រឿងញៀនចំនួន០៣កញ្ចប់លើខ្លួនឈ្មោះ **បមរ**។ ខ្លួនមិនមានថ្នាំញៀនជាប់ខ្លួនទេ។ កន្លងមកខ្លួនធ្លាប់ប្រើប្រាស់ថ្នាំញៀនជាមួយឈ្មោះ **បមរ** ដោយប្រើប្រាស់នៅតាមផ្ទះសំណាក់ ហើយថ្នាំញៀននោះជារបស់ឈ្មោះ **បមរ**។ កន្លងមកមិនធ្លាប់យកថ្នាំញៀនទៅប្រើប្រាស់នៅផ្ទះខ្លួនទេ។ ខ្លួនមិនដឹងថាឈ្មោះ **បមរ** ជាអ្នកលក់ថ្នាំញៀនទេ គ្រាន់តែដឹងថាគាត់ប្រើប្រាស់ថ្នាំញៀន។ ខ្លួនទាក់ទងជាមួយឈ្មោះ **បមរ** បាន៣ខែហើយ ខ្លួនមិនធ្លាប់ឃើញឈ្មោះ **បមរ** លក់គ្រឿងញៀនទេ ។ ចម្លើយដែលខ្លួនបានឆ្លើយនៅចំពោះមុខតំណាងអយ្យការ និងចៅក្រមស៊ើបសួរខ្លួនទទួលស្គាល់ ប៉ុន្តែចំពោះចម្លើយនៅមុខសមត្ថកិច្ច មិនទទួលស្គាល់ទេ។

-ជនជាប់ចោទឈ្មោះ **បមរ** បានឆ្លើយសារភាពថាៈ សមត្ថកិច្ចឃាត់ខ្លួនកាលពីថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៨ មូលហេតុជួញដូរសារធាតុញៀន។ ខ្លួនពិតជាបានជួញដូរសារធាតុញៀនមែន ចាប់តាំងពីឆ្នាំ២០១៨ មកទិញពីបុរសម្នាក់មិនស្គាល់ឈ្មោះ ស្គាល់ទៅលេខទូរស័ព្ទ។ ពេលឃាត់ខ្លួនសមត្ថកិច្ចដកហូតបានថ្នាំចំនួន ០៥ កញ្ចប់តូច។ ពេលទិញរាល់ដង ៥កញ្ចប់តម្លៃ ២៥ម៉ឺនរៀល ដោយខ្លួនផ្ញើរប្រាក់ឲ្យគេមុន ហើយគេយកថ្នាំញៀន

មកផ្លុងចោលនៅវត្តធម្មយុត្តិ។ ខ្លួនស្គាល់ឈ្មោះ **លសខ** ហើយធ្លាប់ប្រើប្រាស់ថ្នាំជាមួយគ្នាប្រហែល ២ទៅ៣ដង នៅបន្ទប់ជួល។ ឈ្មោះ **លសខ** ដឹងថាខ្លួនលក់គ្រឿងញៀន ដោយខ្លួនជាអ្នកប្រាប់។ ខ្លួនធ្លាប់ស្គាល់ឈ្មោះ **យសអ** ឈ្មោះ **វយស** និងឈ្មោះ **អបល** ទេ។ នៅថ្ងៃទី០៥ ខែធ្នូឆ្នាំ២០១៨ សមត្ថកិច្ចបានឲ្យខ្លួនតេកម្មង់ថ្នាំញៀនពីអ្នកលក់ ពេលនោះខ្លួនបានទាក់ទងវេរលុយចំនួន២០ម៉ឺនរៀលឲ្យទៅអ្នកលក់ ហើយណាត់គ្នាយកថ្នាំញៀននៅវត្តធម្មយុត្តិ ហើយបន្ទាប់មកសមត្ថកិច្ចក៏បានឃាត់ខ្លួនឈ្មោះ **អបល**។ ខ្លួនមិនបានដឹងថាសមត្ថកិច្ចឃាត់ខ្លួនឈ្មោះ **អបល** បានថ្នាំញៀនប៉ុន្មាននោះទេ។ នៅថ្ងៃកើតហេតុអ្នកនៅរមាសបានកុម្មង់ទិញថ្នាំញៀនពីខ្លួន ពេលនោះខ្លួនបានបបួលឈ្មោះ **លសខ** ទៅជាមួយដែរ ដោយប្រាប់ថាទៅលេងផ្ទះមិត្តភក្តិ ហើយពេលទៅដល់ខ្លួនបានយកថ្នាំញៀនឲ្យទៅគេ ដោយដាក់ឈ្មោះ **លសខ** នៅម្ខាងផ្លូវ ហើយខ្លួនប្រាប់ថាយកទូរស័ព្ទទៅឲ្យមិត្តភក្តិមួយភ្លែត។ ចំពោះឈ្មោះ ...ខ្លួនស្គាល់ព្រោះធ្លាប់ទិញថ្នាំញៀនពីគាត់យូរហើយ ពេលនេះគាត់ឈប់លក់ហើយ។

-ជនជាប់ចោទឈ្មោះ **អបល** បានឆ្លើយសារភាពថា៖ សមត្ថកិច្ចឃាត់ខ្លួនកាលពីថ្ងៃទី០៥ ខែធ្នូឆ្នាំ២០១៨ មូលហេតុឈ្មោះ **យសអ** បានប្រើខ្ញុំឲ្យយកថ្នាំញៀនឲ្យគេម្តងទៀតចំនួន៥កញ្ចប់ នៅជិតមន្ទីរសុរិយោដី ប៉ុន្តែមិនទាន់បានប្រគល់ឲ្យគេផង ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួន។ ខ្លួនធ្លាប់យកថ្នាំញៀនឲ្យឈ្មោះ **យសអ** បានប្រហែល៥ដង មកហើយ ដោយគាត់ឲ្យថ្នាំញៀនមកប្រើជាថ្លៃឈ្នួល។ ខ្លួនមិនស្គាល់ឈ្មោះ**វយស**ឈ្មោះ **បមរ** និងឈ្មោះ **លសខ** ទេ។ ពេលយកថ្នាំញៀនឲ្យគេ គឺមានគេយកថ្នាំញៀនមកផ្លុងចោលនៅម្តុំសាលាក្រុង រួចហើយទើបឈ្មោះ **យសអ**ទូរស័ព្ទប្រាប់ខ្លួនឲ្យទៅរើសនិងឲ្យលេខទូរស័ព្ទអ្នកទិញមកឲ្យខ្លួន។ កន្លងមកឈ្មោះ **យសអ**ធ្លាប់ប្រើខ្លួនឲ្យទៅយកថ្នាំញៀននៅមុខផ្ទះរបស់ឈ្មោះ **វយស** ម្តង ហើយនៅពេលសមត្ថកិច្ចឃាត់ខ្លួនឲ្យជួយនាំទៅចាប់ខ្លួនអ្នកលក់គ្រឿងញៀនទើបខ្លួននាំសមត្ថកិច្ចទៅផ្ទះរបស់ឈ្មោះ **វយស**។

-ជនជាប់ចោទឈ្មោះ **វយស** បានឆ្លើយសារភាពថា៖ សមត្ថកិច្ចឃាត់ខ្លួនកាលពីថ្ងៃទី០៦ ខែធ្នូឆ្នាំ២០១៨ វេលាម៉ោង១១និង៥០នាទីថ្ងៃត្រង់ ពេលដែលខ្លួនកំពុងនៅផ្ទះ។ ពេលដែលសមត្ថកិច្ចឃាត់ខ្លួនបានដកហូតថ្នាំញៀនពីខ្លួនចំនួន០៤កញ្ចប់ធំ និងថ្នាំគ្រាប់ ១កញ្ចប់ ហើយថ្នាំញៀនទាំងនោះជារបស់ឈ្មោះ...។ ហើយនៅពេលណាមានគេត្រូវការទិញថ្នាំញៀនគឺឈ្មោះ ...ឲ្យគេមកយកពីខ្លួន។ ចំពោះប្រាក់ថ្លៃថ្នាំញៀនខ្លួនមិនដឹងទេ។ ឈ្មោះ... ឲ្យថ្លៃឈ្នួលខ្លួន១ខែ១០០ ដុល្លារ ។ ឈ្មោះ **អបល** ខ្លួនស្គាល់ព្រោះធ្លាប់យកតវ៉ាន់ឲ្យ គាត់។

-លោក...អធិការរងស្រុកទឹកផុសបានបំភ្លឺថា៖ កាលពីថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៨ កម្លាំងសមត្ថកិច្ចបានទទួលព័ត៌មានពីប្រជាពលរដ្ឋថា មានមុខសញ្ញាជួញដូរគ្រឿងញៀន២នាក់ កំពុងធ្វើដំណើរពីខ្លុងពពកទៅរមាស បន្ទាប់មកសមត្ថកិច្ចបានឃាត់ខ្លួនពួកគាត់ទាំង២នាក់ ហើយពួកគាត់ទាំង២នាក់បានសហការណ៍ឈានទៅដល់ការចាប់មេខ្លោងឈ្មោះ **អបល** នៅថ្ងៃទី០៥ បានថ្នាំញៀន១កញ្ចប់ ចំណែកឈ្មោះ **វយស** ឃាត់ខ្លួនថ្ងៃទី០៦ ថ្នាំញៀន១កញ្ចប់ធំ និងថ្នាំគ្រាប់១៨២គ្រាប់។

-អានកំណត់ហេតុសួរចម្លើយរបស់ឈ្មោះ ...៖ ខ្លួនត្រូវសមត្ថកិច្ចឃាត់ខ្លួនកាលពីថ្ងៃទី០៥ ខែធ្នូឆ្នាំ២០១៨ វេលាម៉ោង១១និង៥០នាទីថ្ងៃត្រង់ ពេលកំពុងពរចៅនៅយ៉មុខផ្ទះ។ សមត្ថកិច្ចឃាត់ខ្លួនហើយសុំឆែកឆេរផ្ទះ ពុំមានអ្វីទេ រួចខ្លួនសួរថាខ្លួនខុសអី រួចគាត់ប្រាប់ថានៅឲ្យស្ងៀមទៅ បន្ទាប់មកនាំខ្លួនមកស្នងការតែម្តង ។ ចំពោះការចោទប្រកាន់ខ្លួនក្នុងរឿងជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀននោះមិនពិតទេ។ សមត្ថកិច្ចបានដកហូតទូរស័ព្ទចុចពិល និងម៉ូតូ១គ្រឿង ។ ខ្លួនសំណូមពរដល់តុលាការជួយរកយុត្តិធម៌ផង។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖ ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ និងការបំភ្លឺរបស់សមត្ថកិច្ច ឃើញថាកាលពីថ្ងៃទី០៤-០៥-០៦ ខែធ្នូ ឆ្នាំ២០១៨ នៅចំណុចភូមិស្រែតាដៃ ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ពិតជាមានករណីជួញដូរនូវសារធាតុញៀនប្រាកដមែន។

-លោក...មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ **យសអ** បានធ្វើសេចក្តីសន្និដ្ឋានថា៖ បើពិនិត្យតាមសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ប្តឹងសុំតាមមាត្រា៤០ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន គឺសមរម្យហើយ ព្រោះថាទំនងដែរដោយផ្អែកតាមធាតុសុទ្ធនៃថ្នាំញៀន និងផ្អែកលើចម្លើយរបស់ឈ្មោះ **អបល** ។ សុំឲ្យតុលាការជឿលើចម្លើយរបស់ឈ្មោះ...ដែលគាត់បានឆ្លើយថាធ្លាប់ជក់ លក់ថ្នាំផង ហេតុអ្វីចៅក្រមស៊ើបសួរសម្រេចលើកលែងការចោទប្រកាន់ អញ្ចឹងវាអយុត្តិធម៌សម្រាប់កូនក្តីខ្លួនណាស់ សុំតុលាការអនុវត្តស្តង់ដាតែមួយបានហើយ កុំអនុវត្តស្តង់ដាពីរ។ ពុំមានភស្តុតាងដាក់បន្ទុកលើកូនក្តីខ្លួនរបស់ខ្លួនឈ្មោះ **យសអ** នោះទេ សុំតុលាការមេត្តាឲ្យកូនក្តីរបស់ខ្លួនរួចខ្លួនពីបទចោទ ព្រោះរឿងខាងលើមានវិមតិសង្ស័យលើកូនក្តីរបស់ខ្លួន ។

-លោក ...មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ **វយស** ឈ្មោះ **បមរ** និងឈ្មោះ **លសខ** បានធ្វើសេចក្តីសន្និដ្ឋានថា៖ ស្នើសុំតុលាការបន្ធូរបន្ថយទោសដល់កូនក្តីរបស់ខ្លួនឈ្មោះ **បមរ** ដោយសារឈ្មោះ **បមរ** បានសហការណ៍ជាមួយសមត្ថកិច្ចរហូតឈានទៅដល់ការឃាត់ខ្លួនអ្នកជួញដូរផ្សេងទៀត។ ចំណែកឈ្មោះ **លសខ** មិនបានចូលស៊ីជម្រៅក្នុងរឿងហេតុខាងលើនេះទេ សុំតុលាការបន្ធូរបន្ថយទោសជាអប្បបរមាផង និងស្នើសុំស្ពានសម្រាលដល់ឈ្មោះ **វយស** ផង ព្រោះគាត់បានសារភាពជូនតុលាការ។

-លោក...មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ **អបល** បានធ្វើសេចក្តីសន្និដ្ឋានថា៖ កូនក្តីរបស់ខ្លួនបានសារភាព សុំតុលាការបន្ធូរបន្ថយទោសដល់កូនក្តីរបស់ខ្លួនផង ព្រោះគាត់បានសហការណ៍ជាមួយសមត្ថកិច្ចរហូតឈានទៅដល់ការឃាត់ខ្លួនឈ្មោះ **វយស** ទៀតងផង។ សុំផ្តន្ទាទោសកូនក្តីខ្លួន១ឆ្នាំបានហើយ ព្រោះគាត់បានសារភាព និងសហការណ៍ ។

-ជនជាប់ចោទឈ្មោះ **វយស** មិនមានសំណូមពរអ្វីចុងក្រោយទេ ។

-ជនជាប់ចោទឈ្មោះ **អបល** ឈ្មោះ **បមរ** និងឈ្មោះ **លសខ** បានធ្វើសំណូមពរ ជាសម្ដីចុងក្រោយថា សុំតុលាការបន្ធូរបន្ថយទោសឲ្យខ្លួនផង ។

-ក្រោយពីបានស្ដាប់ម្លើយរបស់ជនត្រូវចោទ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានស្ដាប់ជនជាប់ចោទនិយាយសម្ដីចុងក្រោយ

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## សាលាដំបូងខេត្តកំពង់ឆ្នាំង

## យល់ឃើញថា

១.កាលពីថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៨ នៅចំណុចផ្លូវជាតិលេខ៥៣ ស្ថិតក្នុងភូមិស្រែតាដៃ ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង កម្លាំងសមត្ថកិច្ចបានឃាត់ខ្លួនជនជាប់ចោទឈ្មោះ **បមរ** ភេទប្រុស ឈ្មោះ **លសខ** ភេទស្រី ឈ្មោះ **អបល** ភេទប្រុស និងឈ្មោះ **វយស** ភេទប្រុស ព្រមទាំងដកហូតបានម្សៅក្រាមសថ្លា សារធាតុញៀនមេតំហ្វេតាមីនសរុបសំនួន៩៦កញ្ចប់ សរុប(ទម្ងន់ ២៧០,១៦ក្រាម) ថ្នាំញៀនប្រភេទ WY ចំនួន១៨២គ្រាប់ ទម្ងន់(១៩,៦០ក្រាម) ទូរស័ព្ទចំនួន០៤គ្រឿង និងម៉ូតូចំនួន០២គ្រឿង ចំណែកឈ្មោះ **យសអ** បានគេចខ្លួន។

២.ចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ **បមរ** ភេទប្រុស ឈ្មោះ **លសខ** ភេទស្រី ឈ្មោះ **អបល** ភេទប្រុស និងឈ្មោះ **វយស** ភេទប្រុស មានភាពស៊ីសង្វាក់គ្នាជាមួយរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងវត្ថុតាង ដែលដកហូតបានពីជនជាប់ចោទ អាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ **បមរ** ភេទប្រុស ឈ្មោះ **លសខ** ភេទស្រី ឈ្មោះ **អបល** ភេទប្រុស ឈ្មោះ **វយស** ភេទប្រុស និងឈ្មោះ **យសអ** ភេទប្រុស ពិតជាបានធ្វើសកម្មភាពរក្សាទុក ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន ។

៣.តាមចម្លើយរបស់ឈ្មោះ **អបល** និងរបាយការណ៍សំយោគលេខ៣៧៦/២០១៨ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ របស់ការិយាល័យប្រឆាំងគ្រឿងញៀននៃស្នងការដ្ឋានខេត្តកំពង់ឆ្នាំង ឃើញថាគ្រឿងញៀនដែលឈ្មោះ **អបល** យកទៅលក់នោះគឺបានតាមរយៈឈ្មោះ **យសអ**។

៤.វត្ថុតាងជាក្រាមពណ៌សថ្លា ដែលមានសារធាតុញៀនមេតំហ្វេតាមីនទម្ងន់សរុប ១៧,៥៧ក្រាម ដែលសមត្ថកិច្ចដកហូតពីឈ្មោះ **អបល** គឺជាភស្តុតាងស៊ីសង្វាក់គ្នាមួយដែលបង្ហាញពីការប្រព្រឹត្តបទល្មើសរបស់ជនជាប់ចោទ អាចឲ្យតុលាការជឿបានថា ជនជាប់ចោទឈ្មោះ **អបល** និងឈ្មោះ **យសអ** ពិតជាបានប្រព្រឹត្តបទល្មើស រក្សាទុក ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន។

៥.វត្ថុតាងជាក្រាមពណ៌សថ្លា ដែលមានសារធាតុមេតំហ្វេតាមីនទម្ងន់សរុប ១,៧១ក្រាម ដែលសមត្ថកិច្ចដកហូតពីឈ្មោះ **បមរ** គឺជាភស្តុតាងស៊ីសង្វាក់គ្នាមួយដែលបង្ហាញពីការប្រព្រឹត្តបទល្មើសរបស់ជនជាប់ចោទ អាចឲ្យតុលាការជឿបានថា ជនជាប់ចោទឈ្មោះ **បមរ** និងឈ្មោះ **លសខ** ពិតជាបានប្រព្រឹត្តបទល្មើស រក្សាទុក ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀនប្រាកដមែន។

៦.វត្ថុតាងជាក្រាមពណ៌សថ្លា ដែលមានសារធាតុមេតំហ្វេតាមីនទម្ងន់សរុប ២៥០,៨៨ ក្រាម និងថ្នាំគ្រាប់ ដែលមានសារធាតុមេតំហ្វេតាមីន (យ៉ាបាឬថ្នាំឆ្កួត) ១៨២ គ្រាប់ ស្មើនឹង ១៩,៦០ ក្រាម ដែលសមត្ថកិច្ចដកហូតពីឈ្មោះ **វយស** គឺជាភស្តុតាងស៊ីសង្វាក់គ្នាមួយដែលបង្ហាញពីការប្រព្រឹត្តបទល្មើសរបស់ជនជាប់ចោទ អាចឲ្យ តុលាការជឿបានបានថា ជនជាប់ចោទឈ្មោះ **វយស** ពិតជាបានប្រព្រឹត្តបទល្មើស រក្សាទុក ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀនប្រាកដមែន។

៧.តាមការពិនិត្យ លទ្ធផលកោសល្យវិច័យគ្រឿងញៀនលេខ ១៧១៥៧/១៩ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៩ របស់មន្ទីរពិសោធន៍នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលដកហូតបានពីជនជាប់ចោទឈ្មោះ **អបល** បញ្ជាក់ថា សំណាកគ្រឿងញៀន ប្រភេទក្រាមពណ៌សថ្លា ដែលមានសារធាតុញៀនឈ្មោះមេតំហ្វេតាមីន (ហៅក្រៅអាយ ឬម៉ាទឹកកក) វាស្ថិតក្នុងតាងរាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀនដូចមានចែងលម្អិត ក្នុងតារាងឧបសម្ព័ន្ធច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ដូច្នេះថ្នាំញៀនដែលដកហូតពីឈ្មោះ **អបល** មានកម្រិតភាពសុទ្ធចំនួន ១៤,១០៦ ក្រាម និងភស្តុតាងផ្សេងទៀត អាចឲ្យតុលាការកំណត់បានថា ជនជាប់ចោទឈ្មោះ **អបល** និងឈ្មោះ **យសអ**ពិតជាបានប្រព្រឹត្តអំពើ រក្សាទុក ដឹកជញ្ជូន និងជួញដូរខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន អំពើនេះជាបទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៨.តាមការពិនិត្យ លទ្ធផលកោសល្យវិច័យគ្រឿងញៀនលេខ ១៧១៥៨/១៩ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៩ របស់មន្ទីរពិសោធន៍នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលដកហូតបានពីជនជាប់ចោទឈ្មោះ **បមរ** បញ្ជាក់ថា សំណាកគ្រឿងញៀន ប្រភេទក្រាមពណ៌សថ្លា ដែលមានសារធាតុញៀនឈ្មោះមេតំហ្វេតាមីន (ហៅក្រៅអាយ ឬម៉ាទឹកកក) វាស្ថិតក្នុងតាងរាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀនដូចមានចែងលម្អិត ក្នុងតារាងឧបសម្ព័ន្ធច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ដូច្នេះថ្នាំញៀនដែលដកហូតពីឈ្មោះ **បមរ**មានកម្រិតភាពសុទ្ធចំនួន ១,៣៥ក្រាម និងភស្តុតាងផ្សេងទៀត អាចឲ្យតុលាការកំណត់បានថា ជនជាប់ចោទឈ្មោះ **បមរ** និងឈ្មោះ **លសខ** ពិតជាបានប្រព្រឹត្តអំពើ រក្សាទុក ដឹកជញ្ជូន និងជួញដូរខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន អំពើនេះជាបទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៩.តាមការពិនិត្យ លទ្ធផលកោសល្យវិច័យគ្រឿងញៀនលេខ ១៧១៥៩/១៩ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី ០៤ ខែមីនា ឆ្នាំ២០១៩ របស់មន្ទីពិសោធន៍នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលដកហូតបានពីជនជាប់ចោទឈ្មោះ ***វយស*** បញ្ជាក់ថា សំណាកទី១ ជាគ្រឿងញៀន ប្រភេទក្រាមពណ៌សថ្លា ដែលមានសារធាតុញៀនឈ្មោះមេតំហ្វេតាមីន (ហៅក្រៅអាយ ឬម៉ាទឹកកក) វាស្ថិតក្នុងតាងរាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិត ក្នុងតារាងឧបសម្ព័ន្ធច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ដូច្នេះថ្នាំញៀនដែលដកហូតពីឈ្មោះ ***វយស*** មានកម្រិតភាពសុទ្ធចំនួន ៣,៣៣៩ ក្រាម និងភស្តុតាងផ្សេងទៀត អាចឲ្យតុលាការកំណត់បានថា ជនជាប់ចោទឈ្មោះ ***វយស*** ពិតជាបានប្រព្រឹត្តអំពើ រក្សាទុក ដឹកជញ្ជូន និងជួញដូរខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន អំពើនេះជាបទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១០.ជនជាប់ចោទឈ្មោះ **បមរ** ភេទប្រុស ឈ្មោះ **លសខ** ភេទស្រី ឈ្មោះ **អបល**ភេទប្រុស ឈ្មោះ ***វយស*** ភេទប្រុស និងឈ្មោះ **យសអ** ភេទប្រុស ក្នុងពេលប្រព្រឹត្តបទល្មើស ជននេះមានសមត្ថភាព លទ្ធភាពគ្រប់គ្រាន់ ក្នុងការទទួលខុសត្រូវនូវអំពើល្មើសរបស់ខ្លួនចំពោះមុខច្បាប់ព្រហ្មទណ្ឌជាធរមាន។

១១.អំពើរបស់ជនជាប់ចោទឈ្មោះ **បមរ** ភេទប្រុស ឈ្មោះ **លសខ**ភេទស្រី ឈ្មោះ **អបល** ភេទប្រុស និងឈ្មោះ **យសអ** ភេទប្រុស បានបង្ហាញឲ្យឃើញថា គ្រប់សកម្មភាពមុន និងក្នុងពេលប្រព្រឹត្ត ក៏ដូចជាក្រោយពេលប្រព្រឹត្ត ជនជាប់ចោទរូបនេះមានចេតនាទុច្ចរិត ដែលការប្រព្រឹត្តនេះធ្វើឲ្យខូចខាតនូវរបៀបរៀបរយសាធារណៈ សណ្តាប់ធ្នាប់សង្គម និងប៉ះពាល់ដល់នីត្យានុកូលភាពសង្គម និងបំពានលើមាត្រា៤០កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១២.អំពើរបស់ជនជាប់ចោទឈ្មោះ ***វយស*** បានបង្ហាញឲ្យឃើញថា គ្រប់សកម្មភាពមុន និងក្នុងពេលប្រព្រឹត្ត ក៏ដូចជាក្រោយពេលប្រព្រឹត្ត ជនជាប់ចោទរូបនេះមានចេតនាទុច្ចរិត ដែលការប្រព្រឹត្តនេះធ្វើឲ្យខូចខាតនូវរបៀបរៀបរយសាធារណៈ សណ្តាប់ធ្នាប់សង្គម និងប៉ះពាល់ដល់នីត្យានុកូលភាពសង្គម និងបំពានលើមាត្រា ៤០ កថាខណ្ឌទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១៣.មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាប់លើឈ្មោះ **បមរ** ភេទប្រុស ឈ្មោះ **លសខ** ភេទស្រី ឈ្មោះ **អបល** ភេទប្រុស និងឈ្មោះ **យសអ** ភេទប្រុស ពីបទ រក្សាទុក ដឹកជញ្ជូន និងជួញដូរខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចភូមិស្រែតាដៃ ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី០៤-០៥-០៦ ខែធ្នូ ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១៤.មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាប់លើឈ្មោះ ***វយស*** ភេទប្រុស ពីបទ រក្សាទុក ដឹកជញ្ជូន និងជួញដូរខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចភូមិស្រែតាដៃ ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស

ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី០៤-០៥-០៦ ខែធ្នូ ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១៥.វត្ថុចាប់យក៖ ដូចមានក្នុងដីកាបង្គាប់ឲ្យតម្កល់វត្ថុតាងលេខ២៤៨៣ អ.យ/២០១៨ គប្បីរឹបអូសតាមបញ្ញត្តិមាត្រា៩៣ មាត្រា៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា៦២ មាត្រា៦៣ នៃក្រមព្រហ្មទណ្ឌ ។

១៦.សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ទៅលើជនជាប់ចោទខាងលើ មានភស្តុតាងដាក់វន្ទុកគ្រប់គ្រាន់អាចឲ្យតុលាការលើកយកមកពិចារណាបាន។

១៧.សេចក្តីសន្និដ្ឋានរបស់លោក...មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ **យសអ** សុំឲ្យកូនក្តីខ្លួនរួចផុតពីបទចោទនោះ មិនមានភស្តុតាងអ្វីសំអាងគ្រប់គ្រាន់ អាចឲ្យតុលាការលើកយកមកពិចារណាបានឡើយ ។

១៨.សេចក្តីសន្និដ្ឋានរបស់លោក ...និងលោក..មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ**បមរ** ភេទប្រុស ឈ្មោះ **លសខ** ភេទស្រី ឈ្មោះ **អបល** ភេទប្រុស ឈ្មោះ ***វយស*** ភេទប្រុស សុំឲ្យតុលាការបន្ធូរបន្ថយទោសដល់កូនក្តីខ្លួន អាចឲ្យតុលាការលើកយកមកពិចារណាបាន ។

១៩.ជនជាប់ចោទឈ្មោះ ***វយស*** មិនមានសំណូមពរធ្វើឡើយ គប្បីតុលាការមិនលើកយកមកពិចារណាក្នុងការសម្រេចសេចក្តីនោះទេ ។

២០.សម្តីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ**បមរ** ភេទប្រុស ឈ្មោះ **លសខ** ភេទស្រី និងឈ្មោះ **អបល** ភេទប្រុស ឲ្យតុលាការបន្ធូរបន្ថយទោស គប្បីតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី ។

## ហេតុដូច្នេះសម្រេច

១.ជនជាប់ចោទ៖

ក.ឈ្មោះ ***វយស*** ភេទប្រុស អាយុ៣៣ឆ្នាំ មានពិរុទ្ធភាពពីបទ រក្សាទុក ដឹកជញ្ជូន និងជួញដូរខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិស្រែតាជៃ ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី០៤-០៥-០៦ ខែធ្នូ ឆ្នាំ២០១៨ ។

ខ.ឈ្មោះ **អបល** ភេទប្រុស អាយុ២៣ឆ្នាំ

គ.ឈ្មោះ**បមរ** ភេទប្រុស អាយុ២៨ឆ្នាំ

ឃ.ឈ្មោះ **លសខ** ហៅ ពៅ ភេទស្រី អាយុ២៣ឆ្នាំ

ង.ឈ្មោះ **យសអ** ភេទប្រុស អាយុ៣៧ឆ្នាំ

មានពិរុទ្ធភាពពីបទ រក្សាទុក ដឹកជញ្ជូន និងជួញដូរខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិស្រែតាជៃ ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី០៤-០៥-០៦ ខែធ្នូ ឆ្នាំ២០១៨ ។

២.ផ្តន្ទាទោសៈ

ក.ឈ្មោះ **វយស** ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិវៀតណាម ដាក់ពន្ធនាគារកំណត់ ១៥(ដប់ប្រាំ)ឆ្នាំ ពីបទ រក្សាទុក ដឹកជញ្ជូន និងជួញដូរខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិស្រែតាដៃ ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី០៤-០៥-០៦ ខែធ្នូ ឆ្នាំ២០១៨ ។

ខ/.ឈ្មោះ **អបល** ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០៤(បួន)ឆ្នាំ ។

គ/.ឈ្មោះ **បមរ** ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០២(ពីរ)ឆ្នាំ និង ០៦ (ប្រាំមួយ)ខែ ។

ឃ/.ឈ្មោះ**លសខ** ភេទស្រី អាយុ២៣ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០២(ពីរ)ឆ្នាំ និង ០៦ (ប្រាំមួយ)ខែ ។

ង/.ឈ្មោះ **យសអ** ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០៣(បី)ឆ្នាំ។

**ពីបទ រក្សាទុក ដឹកជញ្ជូន និងជួញដូរខុសច្បាប់នូវសារធាតុញៀន** តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិស្រែតាដៃ ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី០៤-០៥-០៦ ខែធ្នូ ឆ្នាំ២០១៨ ។

៣.បង្គាប់ឲ្យចាប់ខ្លួនឈ្មោះ**យសអ** ដែលមានសាវតារជាតិខាងលើ ។

៤.រឹបអូសវត្ថុតាងមានក្នុងសាលដីកាបង្គាប់ឲ្យតម្កល់វត្ថុតាងលេខ ២៤៨៣ អ.យ/២០១៨ តាមបញ្ញត្តិមាត្រា៩៣ និងមាត្រា៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, មាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទ ឈ្មោះ **វយស**, ឈ្មោះ **អបល** ឈ្មោះ **បមរ** និងឈ្មោះ **លសខ** ។ កំបាំងមុខជនជាប់ចោទ ឈ្មោះ **យសអ** និង ប្រកាសជាសាធារណៈនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ ទុកសិទ្ធិឲ្យប្តឹងទាស់និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ... | ... | ... | ... |